*សម្រាប់ផ្សព្វផ្សាយភ្លាមៗ*

# ការស្វែងរកមតិគាំទ្រលើការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក ជម្រុញឲ្យមានសកម្មភាព និងគោលនយោបាយអាទិភាព

*រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣*

អង្គការសម្ព័ន្ធដើម្បីសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងអង្គការជនពិការអន្តរជាតិ ដោយមានការគាំទ្រថវិកាពីអង្គការដៃគូសុវត្ថិភាពចរាចរណ៍ផ្លូវគោកសកល បានរួមគ្នាជាមួយនឹងអង្គការមូលនិធិបង្ការរបួស អាស៊ី ក្នុងការបន្តអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជាឲ្យពិនិត្យលទ្ធភាពចាត់វិធានការជាបន្ទាន់ សំដៅទប់ស្កាត់កំណើននៃការស្លាប់ដោយគ្រោះថ្នាក់ចរាចណ៍ផ្លូវគោក។ តំណាងប្រព័ន្ធផ្សព្វផ្សាយ និងអ្នកទាក់ទាញមតិគាំទ្រលើការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក ប្រមាណ ៩០នាក់ បានចូលរួមការអំពាវនាវខាងលើនេះនៅក្នុងសន្និសិទសារព័ត៌មានមួយនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣។

មានមនុស្សជិត ២ ០០០នាក់ បានបាត់បង់ជីវិត និងប្រមាណជាង១៣ ០០០នាក់ផ្សេងទៀតបានទទួលរងរបួសជារៀងរាល់ឆ្នាំនៅលើដងផ្លូវក្នុងប្រទេសកម្ពុជា។ កញ្ញា លឹម សុខជា នាយិកាប្រតិបត្តិអង្គការសម្ព័ន្ធដើម្បីសុវត្ថិភាពចរាចរណ៍ផ្លូវគោកបានមានប្រសាសន៍ថា៖ "៨៣% នៃអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក គឺជាអ្នកប្រើប្រាស់ផ្លូវងាយរងគ្រោះ ដែលរួមមានអ្នកធ្វើដំណើរតាមទោចក្រយានយន្ត អ្នកជិះកង់ និងអ្នកថ្មើរជើង"។ កញ្ញាក៏បានមានប្រសាសន៍បន្ថែមថា៖ "តាមរយៈការចាត់វិធានការដ៏មានប្រសិទ្ធិភាពដើម្បីការពារអ្នកប្រើប្រាស់ផ្លូវទាំងនេះ វាពិតជាគ្មានការសង្ស័យឡើយដែលប្រទេសកម្ពុជាអាចជួយសង្គ្រោះជីវិតមនុស្សបានរាប់ពាន់នាក់ពីគ្រោះថ្នាក់ចរាចរណ៍"។

យោងតាមរបាយការណ៍បឋមបានបង្ហាញថា មានអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកកាលពីឆ្នាំ២០១២ ប្រមាណ ៦៨% ជាអ្នកធ្វើដំណើរតាមទោចក្រយានយន្ត ហើយ ៦៦% នៃពួកគេទទួលរងរបួសក្បាល។ លោក គឹម បញ្ញា នាយកអង្គការមូលនិធិបង្ការរបួស អាស៊ីប្រចាំនៅកម្ពុជាបានមានប្រសាសន៍ថា៖ "អ្វីដែលរឿងគួរឲ្យសោកសៅនោះគឺថា ការស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍មួយចំនួនធំពិតជាអាចទប់ស្កាត់បាន"។ លោកក៏បានមានប្រសាសន៍បន្ថែមថា៖ "ការពាក់មួកសុវត្ថិភាពត្រូវបានបញ្ជាក់បង្ហាញថា អាចកាត់បន្ថយអត្រា

រងរបួសធ្ងន់ធ្ងរបានរហូតដល់ ៦៩% និងកាត់បន្ថយអត្រាស្លាប់បានរហូតដល់ ៤២% នៅពេលមានគ្រោះថ្នាក់ចរាចរណ៍កើតឡើង។ ប៉ុន្តែខណៈពេលដែលមានអ្នកបើកបរទោចក្រយានយន្តច្រើនជាង ៦០% បានពាក់មួកសុវត្ថិភាព មានអ្នករួមដំណើរតាមទោចក្រយានយន្តតិចជាង ១០% បានពាក់មួកសុវត្ថិភាព។

ដើម្បីឆ្លើយតបទៅនឹងស្ថានភាពគ្រោះថ្នាក់ចរាចរណ៍ដ៏គួរឲ្យរន្ធត់នេះ មានដៃគូពាក់ពន្ធ័ច្រើនជាង ១០០ មកពីវិស័យឯកជន អង្គការសង្គមស៊ីវិល និងសហគមន៍អន្តរជាតិ បានគាំទ្រលើសេចក្តីថ្លែងការណ៍រួមមួយ ដោយបានស្នើសុំដោយទទូចដល់រាជរដ្ឋាភិបាលកម្ពុជាឲ្យពិនិត្យលទ្ធភាពពន្លឿនការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក (ថ្មី)។ បន្ថែមពីលើនេះ សេចក្តីថ្លែងការណ៍រួម ក៏បានអំពាវនាវដល់ប្រព័ន្ធផ្សព្វផ្សាយចូលរួមលើកកម្ពស់ការផ្សព្វផ្សាយឥរិយាបថនៃការប្រើប្រាស់ផ្លូវដោយសុវត្ថិភាព និងជម្រុញការពាក់មួកសុវត្ថិភាពតាមគ្រប់រូបភាព ហើយវិស័យឯកជនក៏ត្រូវបានលើកទឹកចិត្តឲ្យរៀបចំជាគោលនយោបាយផ្ទៃក្នុងរបស់ខ្លួនក្នុងការជម្រុញបុគ្គលិកឲ្យគោរពច្បាប់ចរាចរណ៍។ មានប្រជាពលរដ្ឋច្រើនជាង ៤ ០០០ នាក់ បានបង្ហាញការគាំទ្រលើសេចក្តីព្រាងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក (ថ្មី) ដែលបានដាក់បញ្ចូលការកំណត់ឲ្យអ្នករួមដំណើរតាមទោចក្រយានយន្ត គិតទាំងកុមារត្រូវតែពាក់មួកសុវត្ថិភាព ដោយការគាំទ្រនេះបានធ្វើឡើងតាមរយៈប្រព័ន្ធអ៊ីនធឺណេត និងការចុះហត្ថលេខាលើផ្ទាំងបដា និងញត្តិគាំទ្រ។

តាមការសិក្សាស្រាវជ្រាវនាពេលថ្មីៗនេះ បានបង្ហាញថាមានប្រជាពលរដ្ឋប្រមាណ ៩៨% បានគាំទ្រចំពោះការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក (ថ្មី) ដែលកំណត់ពីការពាក់មួកសុវត្ថិភាពសម្រាប់អ្នករួមដំណើរតាមទោចក្រយានយន្ត។ លោក គង់ សុវណ្ណ ប្រធានគ្រប់គ្រងកម្មវិធីប្រចាំប្រទេសកម្ពុជារបស់អង្គការដៃគូសុវត្ថិភាពចរាចរណ៍ផ្លូវគោកសកល បានឲ្យដឹងថា៖ "សាធារណៈជនត្រូវតែចាប់ផ្តើមចូលរួមជាសកម្មភាពចាប់ពីឥឡូវនេះទៅ។ សូមកុំរង់ចាំរហូតទាល់តែច្បាប់ត្រូវបានអនុម័ត"។ លោកក៏បានបន្ថែមទៀតថា៖ "តាមរយៈការពាក់មួកសុវត្ថិភាព និងចែករំលែកសារអប់រំដ៏មានសារៈសំខាន់ដល់មនុស្សជាទីស្រលាញ់ មន្ត្រីបុគ្គលិក និងអ្នកអានសារព័ត៌មានរបស់អ្នក មានន័យថាអ្នកបានចូលរួមជួយសង្គ្រោះជីវិតមនុស្សផងដែរ"។

សន្និសិទសារព័ត៌មាននេះក៏បានបង្ហាញអំពីអនុសាសន៍សំខាន់ៗបន្ថែម ដែលផ្អែកលើតឹកតាងសមស្រប ដោយបានផ្តោតលើទិដ្ឋភាពសុវត្ថិភាពចរាចរណ៍ផ្លូវគោកទាំងឡាយ រួមមាន៖ ការ

ផ្តល់សិទ្ធិអំណាចដល់អ្នកប្រើប្រាស់ផ្លូវឆ្លាតវៃតាមរយៈការអប់រំ ការធ្វើឲ្យកាន់តែប្រសើរឡើងនូវការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកដែលនាំឲ្យមានការគោរពបទបញ្ញត្តិចរាចរណ៍ ការកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ប្រកបដោយសុវត្ថិភាព និងការបង្កើតយន្តការឆ្លើយតបនឹងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកបានទាន់ពេលវេលា។

លោក អ៊ា ចរិយា ប្រធានគ្រប់គ្រងកម្មវិធីសុវត្ថិភាពចរាចរណ៍នៃអង្គការជនពិការអន្តរជាតិ បានគូសបញ្ជាក់ថា៖ "វិស័យសុវត្ថិភាពចរាចរណ៍ផ្លូវគោក មិនទាន់ទទួលបានការគាំទ្រជាថវិកាឲ្យគ្រប់គ្រាន់សម្រាប់អនុវត្តការងារឲ្យមានផលវិជ្ជមានជានិរន្តរ៍ សំដៅកាត់បន្ថយការស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍នៅប្រទេសកម្ពុជានោះទេ"។ លោកក៏បានបន្ថែមថា៖ "គ្រោះថ្នាក់ចរាចរណ៍បានធ្វើឲ្យខាតបង់ថវិកាប្រមាណ ៣២៩លានដុល្លាអាមេរិក ក្នុងឆ្នាំ២០១២ ខណៈពេលដែលថវិកាជាតិប្រមាណតែ ១.៧លានដុល្លាសហរដ្ឋអាមេរិកប៉ុណ្ណោះ ត្រូវបានវិនិយោគលើការងារសុវត្ថិភាពរាចរណ៍ផ្លូវគោកក្នុងពេលតំណាលគ្នា។ ការបង្កើនឆន្ទៈនយោបាយ និងធនធានសម្រាប់ធ្វើឲ្យដងផ្លូវមានសុវត្ថិភាព នឹងជួយសង្គ្រោះជីវិតមនុស្ស ទប់ស្កាត់ និងកាត់បន្ថយការរងរបួស និងលើកស្ទួយសេដ្ឋកិច្ចជាតិ។

ព័ត៌មានបន្ថែម សូមទំនាក់ទំនង:

**អង្គការសម្ព័ន្ធដើម្បីសុវត្ថិភាពចរាចរណ៍ផ្លូវគោក**
កញ្ញា លឹម សុខជា
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៥៥៥ ១៥៨៣
អ៊ីម៉ែល: lim.sokchea@crysafety.org.kh

**អង្គការជនពិការអន្តរជាតិ**
លោក អ៊ា ចរិយា
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១៧ ២៩៨
អ៊ីម៉ែល: rs.mgr@hicambodia.org

**អង្គការមូលនិធិបង្ការរបួស អាស៊ី**
លោក គឹម បញ្ញា
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩៩៦ ៥១៩

អ៊ីម៉ែល: pagna.kim@aipf-cambodia.org